# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ
## សុន្ទរកថា ឯកឧត្តម តាន់ វុទ្ធា រដ្ឋលេខាធិការ ក្រសួងបរិស្ថាន
## ថ្លែងក្នុងទិវាតំបន់ដីសើមពិភពលោក
## ថ្ងៃទី ០២ កុម្ភៈ ឆ្នាំ ២០០៦
### សួនច្បារ ជ្រោយចង្វា ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ

- ខ្ញុំព្រះករុណាខ្ញុំសូមក្រាបថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សម្តេច ទ្រង់ ឯកឧត្តម អស់លោក-លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ជាទីគោរព
- បងប្អូនប្រជាពលរដ្ឋ ប្អូនៗនិស្សិត និងសិស្សានុសិស្សទាំងអស់ជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានឃើញសភាពផ្ទាល់នូវការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ទ្រង់ ឯកឧត្តម អស់លោក-លោកស្រី បងប្អូនប្រជាពលរដ្ឋ និងប្អូនៗទាំងអស់ក្នុងទិវាតំបន់ដីសើមពិភពលោកនេះ។ ជាការពិតខ្ញុំព្រះករុណា ខ្ញុំក្នុងនាមថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅអស់ពីដួងចិត្តចំពោះការអញ្ជើញចូលរួមជាអធិបតីនៃអ្នកអង្គម្ចាស់តំណាងអាជ្ញាធរក្រុងភ្នំពេញ និងឯកឧត្តមតំណាងស្ថាប័នពាក់ពន្ធ័ដែលបានថ្លែងសុន្ទរកថាចំណាប់អារម្មណ៍ដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅក្នុងកិច្ចប្រារព្ធទិវាតំបន់ដីសើមពិភពលោកថ្ងៃ ០២ កុម្ភៈ ២០០៦ ដែលជាសារមួយបង្កប់នូវអត្ថន័យអប់រំដល់សាធារណជនដើម្បីបុព្វហេតុតំបន់ដីសើមនៅកម្ពុជាមានដំណើរប្រព្រឹត្តទៅដោយចីរភាព។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជំរាបជូន សម្តេច ទ្រង់ ឯកឧត្តម-លោកជំទាវ អស់លោក លោកស្រីជ្រាបថា ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសហត្ថលេខីមួយនៃអនុសញ្ញារ៉ាមសារតាំងពីឆ្នាំ១៩៩៩មកម្ល៉េះហើយ តាមរយៈ អនុសញ្ញានេះបណ្តាប្រទេសហត្ថលេខីទាំងអស់ត្រូវតែរៀបចំនូវគណៈកម្មាធិការជាតិគ្រប់គ្រងតំបន់ដីសើមដែលមានសមាសភាពពីបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធនានាសំរាប់ដឹកនាំ ណែនាំ និងផ្តល់យោបល់ដល់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងតំបន់ដីសើមក្នុងគោលបំណងសំរេចឱ្យបានការអភិរក្ស និងប្រើប្រាស់ឱ្យបានចីរភាព។

ថ្វីបើក្រសួងបរិស្ថាន ជាស្ថាប័នដឹកនាំនិងសំរបសំរួលការអនុវត្តអនុសញ្ញានេះក៏ដោយ ក្រសួងទទួលស្គាល់ថាសកម្មភាពមួយចំនួនធំដែលពាក់ព័ន្ធនឹងតំបន់ដីសើម គឺស្ថិតក្នុងការដឹកនាំ គ្រប់គ្រង និងប្រើប្រាស់ដោយស្ថាប័ននានាជាច្រើន។ និរន្តរភាពតំបន់ដីសើមពុំមែនជាកាទទួលខុសត្រូវរបស់ស្ថាប័នឯករាជ្យណាមួយនោះទេ ផ្ទុយទៅវិញគឺជាការទទួលខុសត្រូវរួមរបស់យើងទាំងអស់គ្នាក្នុងការដឹកនាំ ការផ្តល់យោបល់ និង ការគ្រប់គ្រងលើតំបន់ដីសើមទាំងនោះ។

ដូច្នេះការសំរបសំរួល ការតំរង់ទិសនិងការលើកនូវទិសដៅរួមសំរាប់អភិរក្ស ប្រើប្រាស់ និងគ្រប់គ្រងតំបន់ដីសើមដែលជាតំរូវការរបស់ជាតិ ប្រជាជន សហគមន៍ តំបន់ និងរបស់ពិភពលោកគឺជាកត្តាសំខាន់បំផុតសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពប្រទេសកម្ពុជា និងជាវិធានក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។

ការចូលរួមរបស់ព្រះថេរានុថេរៈ ឯកឧត្តម អស់លោក លោកស្រី បងប្អូនប្រជាពលរដ្ឋ និងប្អូនៗទាំងអស់ក្នុងថ្ងៃនេះគឺ ជាសក្ខីភាពមួយបង្ហាញពីការចូលរួមធានាអោយមានចីរភាព និងនិរន្តរភាពនៃ

បរិស្ថានតំបន់ដីសើមក្នុងការអភិវឌ្ឍន៍ ក៏ដូចជាការលើកស្ទួយជីវភាពរស់នៅរបស់បងប្អូនក្នុងសហគមន៍ជុំវិញអាងទន្លេមេគង្គផងដែរ ។

ប្រធានបទទិវាតំបន់ដីសើម ឆ្នាំ២០០៦ "**ចំពោះមុខភាពក្រីក្រ .... តំបន់ដីសើមជាទីពឹងអាស្រ័យ**" បើយើងក្រឡេកមើលផែនទីនៃការតាំងទីលំនៅរបស់មនុស្សនៅចំណែកណាមួយនៃពិភពលោក និងក្នុងពេលណាមួយនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស យើងនឹងមើលឃើញទីក្រុង និងភូមិភាគច្រើនមានទីតាំងស្ថិតនៅក្បែរតំបន់ដីសើម (ទន្លេ,បឹង) ទីចាប់កំណើតដ៏សំខាន់នៃអរិយធម៌គឺមានទីតាំងនៅតាមជ្រលងទន្លេទាំងអស់ ទីក្រុងភ្នំពេញ វត្ថុបុរាណដែលជាវប្បធម៌ និងជាប្រវត្តិសាស្ត្រ ដូចជាប្រាសាទអង្គរវត្ត ។ល ។ ការតាំងទីលំនៅបែបនេះមិនមែនជាការភ្ញាក់ផ្អើលខ្លាំងក្លានោះទេ ព្រោះយើងមិនអាចរស់នៅដោយគ្មានទឹកបានឡើយ ទន្ទឹមនឹងនេះតំបន់ដីសើមផ្តល់ឱ្យយើងនូវផលប្រយោជន៍ជាច្រើនទៀតដូចជា ទីជំរកដ៏ប្រសើរសំរាប់ការរស់នៅរបស់មនុស្ស សត្វ-រុក្ខជាតិ ជាកន្លែងផ្តល់នូវចំណីអាហារ"ត្រី បន្លែ" ឱសថបុរាណ គមនាគមន៍ ជាកន្លែងប្រវត្តិសាស្ត្រដែលមានតំលៃខាងវប្បធម៌ ទេសចរណ៍ និងជាងនេះទៅទៀតតំបន់ដីសើមដើរតួនាទីក្នុងការផ្តល់នូវមុខរបរ ប្រាក់ចំនូល និងសេវាកម្មជាច្រើនទៀតដល់ជនគ្រប់រូបជាពិសេស សហគមន៍ដែលរស់នៅពឹងអាស្រ័យនឹងតំបន់ដីសើម ។ ដូចដែលឯកឧត្តម អស់លោក-លោកស្រី និងប្អូនៗ ទាំងអស់បានជ្រាប និងដឹងរួចមកហើយថា ទិវាតំបន់ដីសើមពិភពលោកនេះមានគោលបំណងសំខាន់បំផុតគឺដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈពី តំលៃ មុខងារ និងផលប្រយោជន៍ជាទូទៅរបស់តំបន់ដីសើម និងជាពិសេសគឺអនុសញ្ញារ៉ាមសារតែម្តង ។

ដូចសុន្ទរកថា ដែលបានលើកឡើងដោយឯកឧត្តមនាយកម្មវិធី អ្នកអង្គម្ចាស់តំណាងអាជ្ញាធរក្រុងភ្នំពេញ តំណាងគណកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំបន់ដីសើមមានតំលៃ និងតួនាទីយ៉ាងច្រើនលើសលប់ដែលមិនអាចកាត់ថ្លៃបានជារូបមាន ជំរកមនុស្ស សត្វ-រុក្ខជាតិ ប្រព័ន្ធចំណីអាហារ ប្រព័ន្ធទ្រទ្រង់ជីវភាពរបស់ប្រជាជនរហូតដល់រក្សាលំនឹងបរិស្ថាន ។ សុន្ទរកថាបានបង្ហាញយ៉ាងច្បាស់លាស់ថា និរន្តរភាពតំបន់ដីសើមពុំមែនជាការទទួលខុសត្រូវរបស់ស្ថាប័ន ឯករាជ្យណាមួយនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺជាការទទួលខុសត្រូវរួមរបស់យើងទាំងអស់គ្នាដោយត្រូវយល់ដឹង ទទួលថែរក្សា និងការពារប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមនេះកុំឱ្យបាត់បង់មិនថាឡើយផ្នែកសាធារណៈ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងមជ្ឈដ្ឋានអប់រំ ជាពិសេស សហគមន៍មូលដ្ឋានផ្ទាល់តែម្តង ដែលប្រើប្រាស់ និងពឹងផ្អែកផ្ទាល់នូវធនធានទាំងនេះ ។

ឯកឧត្តម អស់លោក លោកស្រី បងប្អូនប្រជាពលរដ្ឋ និងប្អូនៗទាំងអស់ជាទីគោរព រាប់អាន ទិវាតំបន់ដីសើមនេះមិនមែនគ្រាន់តែជានិមិត្តរូបមួយដែលរំឭកឡើងសំរាប់តំបន់ដីសើមប៉ុណ្ណោះទេ តែជាស្មារតីសាមគ្គីជាតិ អន្តរជាតិ និងការចូលរួមក្នុងកិច្ចការពារ និងអភិរក្សតំបន់ដីសើមឱ្យប្រកបដោយ និរន្តរភាព ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យប្រគេន និងជូនចំពោះគណៈអធិបតី សម្តេច ឯកឧត្តម អស់លោក-លោកស្រី និងបងប្អូនជនរួមជាតិយើងទាំងអស់សូមបានទទួលនូវ សុខភាពល្អ ទទួលជោគជ័យគ្រប់ភារកិច្ច និងជីវិតប្រកបដោយភាពសុខដុមរមនាពីការប្រើប្រាស់តំបន់ដីសើមដោយនិរន្តរភាពដើម្បីជាប្រយោជន៍ និងចលករក្នុងកិច្ចការពារ និងអភិរក្សតំបន់ដីសើមប្រទេសកម្ពុជា ។

**ចំពោះមុខនៃភាពក្រីក្រ...តំបន់ដីសើមជាទីពឹងអាស្រ័យ!**

**ជយោ! ស្មារតីទិវាតំបន់ដីសើមពិភពលោក ២ កុម្ភៈ ២០០៦**